# មានចំណេះដឹង មានក្តីសង្ឃឹម និងមានកំលាំងចិត្ត ដើម្បីអោយផុតពីការឆ្លងជំងឺរបេង

## មានចំណេះដឹង...ក៏មានក្តីសង្ឃឹមនិងមានកំលាំងចិត្ត

អត្ថបទដ៏មានសារៈសំខាន់នេះ និងផ្តល់ចំណេះដឹងដើម្បីថែរក្សាខ្លួនឯង អោយផុតពីជំងឺដែលមកបៀតបៀនគឺរោគរបេង និងយុទ្ធវិធីការពារអ្នកជិតខាងដើម្បីអោយផុតពីការគ្រោះថ្នាក់ពីជំងឺរបេង និងជួយដល់ក្តីសង្ឃឹម ហើយកំលាំងចិត្ត។

- ✓ អ្នកជំងឺរបេង។
- ✓ អ្នកឆ្លងជំងឺអេដស៍ឈឺដោយសាមកពីរោគរបេង។
- ✓ អ្នកឆ្លងជំងឺអេដស៍ដែលនៅមិនទាន់ឈឺដោយសាមកពីរោគរបេង។
- ✓ អ្នកដែលជាមុខនាទីថែរក្សាអ្នកជំងឺរបេង។
- ✓ បុគ្គលដែលចាប់អារម្មផ្សេងទៀត។



ឧបត្ថម្ភបោះពុម្ពដោយៈ កម្ពុជា ឆិបរន់ ចំកាត់ ។

ឧបត្ថម្ភបោះពុម្ពដោយ

មូលនិធិស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍ ហើយនិងស្ថាប័ណ្ណស្រាវជ្រាវនៃប្រទេសជប៉ុន។

**មានចំណេះដឹង មានក្តីសង្ឃឹម និងមានកំលាំងចិត្ត ដើម្បីអោយផុតពីការឆ្លងជំងឺរបេង**

ISBN 974-92318-5-6
រៀបរៀងដោយ: មូលនិធិការស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍ និងស្ថាប័ណ្ណស្រាវជ្រាវរោគរបេងនៃប្រទេសជប៉ុន (RIT)។
ឧបត្ថម្ភដោយ: មូលនិធិការពារអេដស៍នៃប្រទេសជប៉ុន (JFAP)។
និពន្ធផ្នែកវិជ្ជាការដោយ:
សាស្ត្រាចារ្យវេជ្ជ:បណ្ឌិត វ៉ៃយវេត នុតប្រាក់យូន(កាកបាតក្រហមប្រទេសថៃ និង សហគមការពាររោគរបេងនៃប្រទេសថៃ)។
លោកវេជ្ជ:បណ្ឌិត វ៉ាត់ ឧថៃវិរៈវិត(មន្ទីពេទ្យឈាងរ៉ាយប្រាក់ឆានុគ្រោះ)។
អ្នកគ្រូពេទ្យផាត់ធះរី ខាន់តិផង្ស(មន្ទីពេទ្យឈាងរ៉ាយប្រាក់ឆានុគ្រោះ)។
លោកវេជ្ជ:បណ្ឌិត ចីរីន ឈូឆូតថាវ៉ន(ស្ថាប័ណ្ណរោគបេះដូង ក្រសួងសុខាភិបាល)។
អ្នកគ្រូពេទ្យ ស៊ីប្រាក់ផា នេត្រនិយម(ផ្នែករោគរបេង មន្ទីគ្រប់គ្រងមេរោគក្រសួងសុខាភិបាល)។
លោកវេជ្ជ:បណ្ឌិត បថុម សះវណ្ណបញ្ញាលើត(ស្ថាប័ណ្ណស្រាវជ្រាវវិទ្យាសាស្ត្រ ក្រសួងសុខាភិបាល)។
Dr. Takashi Yoshiyama(RIT) Dr. Hideki Yanai(RIT)
Dr. Norio Yamada(RIT) Dr. Kunihiko Ito (RIT)
បណ្ណាធិការចាងហ្វាង លោកវេជ្ជ: បណ្ឌិត ជិនតនា ង៉ាមវិទ្យាផង្ស-យ៉ាណៃ។
មន្ទីបណ្ណាធិការ: សាមវៃ លូងជិត,អម៉នរាត់ វិរិយះប្រាក់សុបច្ចក។
សរសេរអត្ថបទដោយ: លោកវេជ្ជ:បណ្ឌិត អនស៊ី ង៉ាមវិទ្យាផង្ស។
ក្រុមទំនាក់ទំនងផលិត: ស្ថាប័ណ្ណជំនាញ ទូរ:,លេខហ្វាក់ ០២-៤៣៣-៣៧៥២។
បោះពុម្ពលើកទី ២: មករា ២០០៧ ចំនួន ២,០០០ ក្បាល
រៀបចាំគំនូរនិងក្បាច់ដាក់នៅលើទំព័រដោយ: បុស្សឌី មៀនផង្ស។
រៀបចំរូបភាពដោយ: ទិផន ថងខាំបៃ,ធម្មស័ក្ស សិទ្ធិផង្សសុទ្ធិ។
បោះពុម្ពនៅ: ក្រុមហ៊ុន ប៊ូលេទិន ទូរស័ព្ទលេខ: (៦៦២) ៦៩០-៣០៨៨ ទូរស័ព្ទដៃ: (៦៦៨) ៧០៤១-៨៦៥៣
កម្មសិទ្ធិ: នាំយកអត្ថន័យនិងន័យ-រូបភាពផ្សេងៗ នៅក្នុងអត្ថបទនេះទៅផ្សព្វផ្សាយ ឬយកទៅបោះពុម្ពថ្មីមិនថាតិចឬច្រើន ត្រូវតែសូមអនុញ្ញាតិពីសំណាក់យើងខ្ញុំដោយត្រូវមានជាលាយលក្ខណ៍អក្សរចេញពីមូលនិធិការស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍
ប្រអប់លេខ: 1050/2 វិថីស្ថានផ្សាបាន ស្រុកមៀង ខេត្តឈាងរាយ 57000
។ទូរស័ព្ទលេខ: 053-752-162
លេខហ្វាក់: 053-752-448 email: thrf@tbhiv.org

" The Chief Editor certifies that the translation of the book from Thai to English is accurate. Although the translated text to other languages has been verified by the medical personnel whose mother tongues are those languages, the Chief Editor can not certify the accuracy of translation to languages other than English."



# រស់នៅជាមួយអេដស៍និងរោគរបេងដោយមានក្តីសង្ឃឹម

ក្រុមអ្នកជំនាញវេជ្ជ:បណ្ឌិតទូទាំងពិភពលោកបានតស៊ូដើម្បីយកក្តីឈ្នះនិងកាត់បន្ថយការកើតទុក្ខផ្តល់អោយអ្នកជំងឺអេដស៍ជាបន្តបន្ទាប់។ និងមានការព្យាយាមដូច្នោះហើយក៏បានសំរេចដូចបំណងធ្វើអោយបច្ចុប្បន្នមានការផ្លាស់ប្តូរដែលជួយធ្វើអោយអ្នកជំងឺអេដស៍មានក្តីសង្ឃឹមនិងកំលាំងចិត្តកាន់តែច្រើនឡើងទៀត។



*អានជីវិតដ៏ពិតប្រាកដនៅលើរូបគំនូរក្នុងរូបមន្តផ្តល់កំលាំងចិត*

ពីមុនមក អ្នកជំងឺអេដស៍គិតថាខ្លួនរបស់គេគ្មានក្តីសង្ឃឹម ឈឺរ៉ាំរៃ ចាំតែសេចក្តីស្លាប់ មិនអាចមានអាយុវែងបន្តទៅទៀត។

តែឥឡូវនេះ មានអ្នកជំងឺអេដស៍ចំនួនជាច្រើនដែលនៅមានជីវិតរស់នៅ ការថែរក្សាសុខភាពតាមដែល លោកគ្រូពេទ្យផ្តលការណែនាំ ដូចជាស្រស់ស្រូបអាហារដែលមានផលប្រយោជន៍ បញ្ចេញកំលាំងកាយ ពេលដែលឈឺស្កាត់ មិនថាឈឺតិចឬខ្លាំងដូចជា គ្រុន ឈឺពោះ ឬឈឺខ្លាំងដូចជារោគរបេងក៏រក្សាបានល្អឡើងវិញបានដែរ អ្នកជំងឺអេដស៍ទើបមិនមែនជាអ្នកគ្មានក្តីសង្ឃឹមនោះទេ។

## មានចំណេះដឹង មានក្ដីសង្ឃឹម និងមានកំលាំងចិត្ត ដើម្បីអោយផុតពីការឆ្លងជំងឺរបេង


ISBN 974-92318-5-6

រៀបរៀងដោយ: មូលនិធិការស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍ និងស្ថាប័ណ្ណស្រាវជ្រាវរោគរបេងនៃប្រទេសជប៉ុន (RIT)។

ឧបត្ថម្ភដោយ: មូលនិធិការពារអេដស៍នៃប្រទេសជប៉ុន (JFAP)។

និពន្ធផ្នែកវិជ្ជាការដោយ:

សាស្ត្រាចារ្យវេជ្ជ:បណ្ឌិត ផ័យវេត នុតប្រាក់យូន(កាកបាតក្រហមប្រទេសថៃ និង សហគមការពាររោគរបេងនៃប្រទេសថៃ)។

លោកវេជ្ជ:បណ្ឌិត វ៉ាត់ ឧថៃវិរ:វិត(មន្ទីពេទ្យឈាងរ៉ាយប្រាក់ផានុគ្រោះ)។

អ្នកគ្រូពេទ្យផាត់ធះរី ខាន់តិផង្ស(មន្ទីពេទ្យឈាងរ៉ាយប្រាក់ផានុគ្រោះ)។

លោកវេជ្ជ:បណ្ឌិត ចិរីន ឈ្យូឆ្វតថាវ៉ន(ស្ថាប័ណ្ណរោគបេះដូង ក្រសួងសុខាភិបាល)។

អ្នកគ្រូពេទ្យ ស៊ីប្រាក់ផា នេត្រនិយម(ផ្នែករោគរបេង មន្ទីគ្រប់គ្រងមេរោគក្រសួងសុខាភិបាល)។

លោកវេជ្ជ:បណ្ឌិត បថុម សះវណ្ណបញ្ញាលើត(ស្ថាប័ណ្ណស្រាវជ្រាវវិទ្យាសាស្ត្រ ក្រសួងសុខាភិបាល)។

Dr. Takashi Yoshiyama(RIT) Dr. Hideki Yanai(RIT)

Dr. Norio Yamada(RIT) Dr. Kunihiko Ito (RIT)

បណ្ណាធិការចាងហ្វាង លោកវេជ្ជ: បណ្ឌិត ជិនគនា ម៉ាមវិទ្យាផង្ស-យ៉ាណៃ។

មន្ទីបណ្ណាធិការ: សាមវៃ លួងជិត,អម៉នរាត់ វីរិយះប្រាក់សុបធូក។

សរសេរអត្ថបទដោយ: លោកវេជ្ជ:បណ្ឌិត អនស៊ុ ម៉ាមវិទ្យាផង្ស។

ក្រុមទំនាក់ទំនងផលិត: ស្ថាប័ណ្ណជំនាញ ទូរ:,លេខហ្វាក់ ០២-៤៣៣-៣៧៥២។

បោះពុម្ពលើកទី ២: មករា ២០០៧ ចំនួន ២,០០០ ក្បាល

រៀបចាំគំនូរនិងក្បាច់ដាក់នៅលើទំព័រដោយ: បុស្សឌី មៀនផង្ស។

រៀបចំរូបភាពដោយ: ទ្វីផន ថងខាំបៃ,ផម្មស័ក្ស សិទ្ធិផង្សសុទ្ធិ។

បោះពុម្ពនៅ: ក្រុមហ៊ុន ប៊ូលេទិន ទូរស័ព្ទលេខ: (៦៦២) ៦៩០-៣០៨៨ ទូរស័ព្ទដៃ: (៦៦៨) ៧០៤១-៨៦៥៣



កម្មសិទ្ធិ: នាំយកអត្ថន័យនិងន័យ-រូបភាពផ្សេងៗ នៅក្នុងអត្ថបទនេះទៅផ្សព្វផ្សាយ ឬយកទៅបោះពុម្ពថ្មីមិនថាតិចឬច្រើន ត្រូវតែសូមអនុញ្ញាតិពីសំណាក់យើងខ្ញុំដោយត្រូវមានជាលាយល័ក្សជាអក្សរចេញពីមូលនិធិការស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍



ប្រអប់លេខ: 1050/2 វិថីស្ថានផ្យាបាន ស្រុកមឿង ខេត្តឈាងរាយ 57000

។ទូរស័ព្ទលេខ: 053-752-162

លេខហ្វាក់: 053-752-448 email: thrf@tbhiv.org


" The Chief Editor certifies that the translation of the book from Thai to English is accurate. Although the translated text to other languages has been verified by the medical personnel whose mother tongues are those languages, the Chief Editor can not certify the accuracy of translation to languages other than English."



# រស់នៅជាមួយអេដស៍និងរោគរបេង ដោយមានក្ដីសង្ឃឹម

ក្រុមអ្នកជំនាញវេជ្ជ:បណ្ឌិតទូទាំងពិភព លោកបានតស៊ូដើម្បីយកក្ដីឈ្នះនិងកាត់បន្ថយការកើតទុក្ខផ្ដល់អោយអ្នកជំងឺអេដស៍ជាបន្តបន្ទាប់។ និងមានការព្យាយាមដូច្នោះហើយក៏បានសំរេចដូចបំណងធ្វើអោយបច្ចុប្បន្នមានការផ្លាស់ប្ដូរដែលជួយធ្វើអោយអ្នកជំងឺអេដស៍មានក្ដីសង្ឃឹមនិងកំលាំងចិត្តកាន់តែច្រើនឡើងទៀត។

ពីមុនមក អ្នកជំងឺអេដស៍គិតថាខ្លួនរបស់គេគ្មានក្ដីសង្ឃឹម ឈឺរាំរៃ ចាំតែសេចក្ដីស្លាប់ មិនអាចមានអាយុវែងបន្តទៅទៀត។

តែឥឡូវនេះ មានអ្នកជំងឺអេដស៍ចំនួនជាច្រើនដែលនៅមានជីវិតរស់នៅ ការថែរក្សាសុខភាពតាមដែល លោកគ្រូទេព្យផ្ដលការណែនាំ ដូចជាស្រស់ស្រូបអាហារដែលមានផលប្រយោជន៍ បញ្ចេញកំលាំងកាយ ពេលដែលឈឺស្កាត់ មិនថាឈឺតិចឬខ្លាំងដូចជា គ្រុន ឈឺពោះ ឬឈឺខ្លាំងដូចជារោគរបេងក៏រក្សាបានល្អឡើងវិញបានដែរ អ្នកជំងឺអេដស៍ទើបមិនមែនជាអ្នកគ្មានក្ដីសង្ឃឹមនោះទេ។



*អានជីវិតដ៏ពិតប្រាកដនៅលើរូបគំនូរ ក្នុងរូបមន្តផ្ដល់កំលាំងចិត*



ពីមុនមក អ្នកជំងឺអេដស៍មានអាយុមិនសូវជាបានយូរ(ខ្លី)និងមានការឈឺចាប់ជារៀងរាល់ថ្ងៃ ពីព្រោះមិនមានថ្នាំការពារមេរោគអេដស៍ សំពាងកាយ(ខ្លួនប្រាណ)មិនមានប្រព័ន្ធការពារដែលនិងត្រូវតស៊ូជាមួយមេរោគផ្សេងៗ ដែលពួកវារួមគ្នាឆក់យកឱកាសប្រយុទ្ធប្រឆាំងធ្វើអោយរាយកាយឈឺចាប់ បន្ទាប់មកមានការរកឃើញ ស្រាវជ្រាវឃើញ ថ្នាំការពារមេរោគវីរុស ថ្នាំទាំងអស់នេះនិងមានតំលៃខ្ពស់ ទើបអ្នកក្រមិនមានឱកាសបានទទួលថ្នាំទាំងនេះ។

តែឥឡូវនេះ មានការស្រាវជ្រាវឃើញថ្នាំមេរោគអេដស៍ដែលមានគុណភាពកាន់តែបានល្អឡើងៗ មកពីការមរមាញឹកស្រាវជ្រាវមិនឈប់មិនឈររបស់ក្រុមវេជ្ជៈបណ្ឌិតទូរទាំងពិភពលោក។ ហើយថ្នាំក៏មានតំលៃចុះថោក ក្នុងបច្ចុប្បន្នអ្នកជំងឺអេដស៍ដែលក្រីក្រក៏មានឱកាសបានទទួលថ្នាំមេរោគវីរុសទាំងនេះដែរ។

ពីមុនមក មេរោគអេដស៍បាននិយាយបានឮថា ឆ្លងមកហើយស្លាប់តែម្យ៉ាងគត់គ្មានផ្លូវរស់ទេ។

តែឥឡូវនេះ ក្រុមវេជ្ជៈបណ្ឌិតបានកត់សំគាល់ថា មេរោគអេដស៍ជារោគរាំរ៉ៃមួយដ៏ពូកតែប៉ុន្នោះ។
រោគដែលវាជាព្យាបាលមិនបានជាដាច់ក៏ដោយ ប៉ុន្តែក៏អាចរក្សាដើម្បីអោយមានជីវិតបានគ្រាន់បើឡើងវិញផងដែរ។





មានសុទិដ្ឋិភាពពីរោគរបេង

ជីវិតរបស់អ្នកជំងឺអេដស៍នៅបច្ចុប្បន្នទើបបានកត់សំគាល់ថា ក្តីសង្ឃឹមនៅមិនទាន់ហួសនៅឡើយទេ។ បើសិនកាន់តែដឹងទាន់ពួកវានូវពេលណា(មេរោគអេដស៍) អ្នកជំងឺអេដស៍ ជីវិតយើងក៏មានឱកាសនិងត្រូវជាសះស្បើយទប់ស្កាត់ដោយខ្លួនឯងបានយូរអង្វែងឡើងវិញ "រោគរបេង" ជាសត្រូវមួយសំខាន់បំផុត របស់អ្នកជំងឺអេដស៍ ពីព្រោះ ១ ភាគ ៣។របស់អ្នកជំងឺអេដស៍និងឈឺស្កាត់ហើយស្លាប់ដោយសារតែរោគរបេង។ រោគរបេងរក្សាជាសះស្បើយដាច់បាន បើសិនមានការយល់ដឹងនិងមានកំលាំងចិត្តក្នុងការព្យាយាមថែរក្សា ដូចមានឧទាហរណ៍ពីខាងលើមក។

# រោគរបេងគឺជាអ្វី ?

## តើបង្កើតឡើងនៅត្រង់ណាបានខ្លះនៅលើខ្លួនប្រាណ

- រោគរបេងគឺជារោគឆ្លងតាមការដកដង្ហើមចូលគ្នាទៅវិញទៅមក ចំឡងឆ្លងតាមមេរោគរបេងគឺជាមេរោគកើតចេញមកពីមេរោគវីរុសមួយប្រភេទ រោគរបេងមិនមែនជារោគហឺត, មិនមែនជារោគរលាកសួត ។
- រោគរបេងកើតឡើងបានភាគច្រើននៅលើរបស់រាងកាយ ដែលឃើញជាញឹកញាប់ ហើយជារោគរបេងចំឡងឆ្លងទៅអ្នកដ៏ទៃបានគឺ តាមរោគសួត។



# តើមេរោគរបេងនៅទីកន្លែងណាខ្លះ ?

## ចូលមកសង្ហិរស់នៅក្នុងរាងកាយបានដូចម្ដេច?



- មេរោគរបេងវាមានទំហំតូចបំផុតទើបយើងមើរមិនឃើញ អន្តែតត្រសែតនៅតាមអាកាសបានយូរ ជាពិសេសនៅតាមអាកាសធាតុ ឬតាមទីកន្លែងផ្សេងៗដែលមិនល្អ ដូចជា បន្ទប់ម៉ាស៊ីនត្រជាក់ បន្ទប់ដែលគ្មានខ្យល់ចេញចូលតាមបង្អួច ទ្វារ។
- អ្នកជំងឺរោគរបេង រោគសួត ដែលនៅមិនទាន់បានទទួលថែរក្សា វាអាចចំឡងឆ្លងមេរោគរបេងទៅតាមខ្យល់ដោយការក្អក តាមការកំហាកស្ដេះ តាមការនិយាយ ឬតាមការសើចសប្បាយ។



- នៅពេលយើងដកដង្ហើមយកអាកាសធាតុដែលមានមេរោគរបេងជាប់មកជាមួយចូលមកក្នុងខ្លួនមេរោគរបេងវានិងនៅក្នុងរាងកាយដោយមិនមានអាការៈផ្សេងៗឡើយ តែសូមប្រាប់ថាលោកអ្នកកំពុងមានប្រព័ន្ធការពារទប់ស្កាត់និងមេរោគនោះបានល្អនៅឡើយ រាងកាយវានិងអាចប្រឆាំងទប់ស្កាត់និងមេរោគមិនអោយវាមកធ្វើចលនាអ្វីបានឡើយ មានតែសង្ងំលួចលាក់ខ្លួននៅដោយស្ងៀមស្ងាត់ នៅលើរាងកាយរបស់អ្នក ប៉ុន្តែលោកអ្នកគ្រាន់តែមានឈ្មោះថា "អ្នកឆ្លងមេរោគរបេង" គឺមានមេរោគរបេងនៅក្នុងរាងកាយ ដោយមិនឈឺស្កាត់ និងមិនចំឡងឆ្លងមេរោគទៅអោយអ្នកដ៏ទៃទៀតបាន។
- នៅពេលដែលប្រព័ន្ធការពាររាងកាយចុះអន់ខ្សោយម្តងបន្តិចៗ ធ្វើអោយមានកំលាំងខ្សោយ ដូចជាអ្នកជំងឺអេដស៍ អ្នកជំងឺរោគទឹកនោមផ្អែម ឬចាស់ជរា មេរោគធ្លាប់លួចសង្ងំដោយស្ងាប់ស្ងាត់ តែឥឡូវនេះពួកវាបានបញ្ចេញឫទ្ធិមកប្រយុទ្ធប្រឆាំង ធ្វើអន្តរាគមដល់សួត ឬរាងកាយផ្សេងៗធ្វើអោយឈឺស្កាត់ មនុស្សជំពូកនេះហៅថា "អ្នកជំងឺរោគរបេង" គឺមានអាការៈឈឺស្កាត់និងចំឡងឆ្លងមេរោគផ្តល់ទៅអ្នកដ៏ទៃ។

*លោកគ្រូពេទ្យប្រាប់ថា ក្នុងមនុស្សចំនួន១០០នាក់ដែលឆ្លងមេរោគរបេង មានត្រឹមតែ១០នាក់តែប៉ុន្មោះដែលត្រូវឈឺស្កាត់ នៅសល់៩០នាក់ទៀត ជាអ្នកមានមេរោគរបេង ទើបមិនបានឈឺហើយនិងមិនបានចំឡងមេរោគ។*



# អ្នកជំងឺរោគរបេង សួត មានអាការៈយ៉ាងដូចម្តេច ?

អ្នកមានជំងឺរោគសួត វាតែងតែមានការក្អករ៉ាំរ៉ៃយូរប្រហែលជា ៣អាទិត្យ ឬពេលក្អកមានឈាមដោយមកជាមួយស្លេះផងដែរ ចុះខ្សោយ មានគ្រុន ចេញញើសនៅពេលយប់ ឈឺដើមទ្រូង ធុញអាហារ ទំងន់ចុះស្រក។ យើងខ្ញុំសូមប្រាប់អោយពិតប្រាកដថា អ្នកណាដែលមានជំងឺរោគរបេង សួត ត្រូវតែយកស្លេះរបស់អ្នកណាគួរអោយសង្ស័យទៅត្រួតពិនិត្យ ឆ្នុះមើរនៅឯមន្ទីពេទ្យ ដើម្បីអោយដឹងថាមានរោគឬមិនមាន។ ការមើរសំបកក្រៅមិនដឹងថាមានរោគឬមិនមាន យើងត្រូវតែពិសោធខ្លួនឯង និងស្តាប់លទ្ធិផលមើរ។

បើមានឆ្លងមេរោគអេដស៍ហើយ មកឆ្លងមេរោគរបេង ឬឈឺដោយសារតែរោគរបេងបន្ថែមទៀត តើត្រូវតែថែរក្សាឬទេ? បានផលប្រយោជន៍ឬទេ? ឬធ្វើអោយខាតពេលវេលាមែនទេ? ។

- ត្រូវតែថែរក្សា ពីព្រោះមេរោគអេដស៍គឺរោគរ៉ាំរ៉ៃ មិនមែនជារោគឆ្លងមកហើយស្លាប់តែប៉ុន្មោះទេ ដូចបានប្រាប់មកហើយពីខាងដើម ដូច្នេះ ទើបមិនគួរអោយអស់ក្តីសង្ឃឹមជាមួយនិងមេរោគរបេងៗដែលជាមេរោគរក្សាជាដាច់បាន។
- សំខាន់បំផុត គឺត្រូវតែថែរក្សារោគរបេង វាអាចនិងជួយអោយក្នុងក្រុមគ្រួសារ ឬអនាព្យាបាលរបស់អ្នកជំងឺដែលនៅរួមគ្នា ធ្វើអោយមានសុវត្ថិភាពការពារមិនអោយឆ្លងមេរោគរបេងពីអ្នកជំងឺ។ នៅពេលអ្នកជំងឺបានទទួលទានថ្នាំបំបាត់របេងហើយ ថ្នាំវាក៏ទៅសម្លាប់មេរោគនិងទប់ស្កាត់រោគរបេងមិនអោយចំឡងឆ្លងទៅអ្នកដ៏ទៃ អ្នកជំងឺមិនត្រូវគិតថា ចំឡងទៅអោយអ្នកដ៏ទៃទៀតឡើយ។

# ធ្វើដូចម្តេចនិងអោយមានសុវត្ថិភាពពីមេរោគរបេង?



- ចំពោះអ្នកមានជំងឺអេដស៍ដែលឈឺបន្តាលមកពីមេរោគរបេង

មេរោគរបេងថែរក្សាជាដាច់បាន ប៉ុន្តែត្រូវមានការយល់ដឹង មានសេចក្តីព្យាយាមនិងកំលាំងចិត្តក្នុងការថែរក្សា ពិព្រោះត្រូវលេបថ្នាំច្រើនប្រភេទ បន្តបន្ទាប់គ្នាតិចបំផុត ៦ខែឡើងទៅ។ បើសិនលេបថ្នាំមិនបានជារៀងរហូត មិនទៀងទាត់ មិនបានជារៀងរាល់ថ្ងៃនិងមិនត្រឹមត្រូវ តាមដែលគ្រូពេទ្យកំណត់ណែនាំ វាធ្វើអោយមេរោគអាចទប់ទល់និងថ្នាំបានវិញ ថែរក្សាមិនបាន ឬក៏អាចឈឺកាន់តែបន្ថែមពីរោគរបេងឡើងទៀត។

- ចំពោះអ្នកមានជំងឺអេដស៍ដែលនៅមិនទាន់ឈឺបន្តាលមកពីមេរោគរបេង

ជៀសវាងការរស់នៅរួមគ្នា និយាយស្តីរួមគ្នា ចំពោះអ្នកដែលកំពុងតែក្អករ៉ាំរ៉ៃ ឬអ្នកជំងឺរោគរបេងដែលនៅមិនទាន់ថែរក្សា ឬកំពុងសង្ស័យចាំចំឡង គឺថែរក្សាមកហើយមិនទាន់បាន៣អាទិត្យ សូមជៀសវាងការនៅជិតជាមួយអ្នកជំងឺនៅពីក្រោមខ្យល់ពេលវេលាយូរ។

- គួរតែទទួលការណែនាំពីគ្រូពេទ្យ ឬអ្នកចេះដឹងដើម្បីលេបថ្នាំការពាររោគរបេង។
- ចាំជួបបុគ្គលិកដើម្បីត្រួតពិនិត្យថែរក្សាភ្លាមបើមានរោគរបេង។

## ណែនាំ ដល់លោកអ្នកគ្រប់ៗរូប



- ➢ យកកូនកន្សែង,ក្រណាត់ ឬក្រដាសទន់ៗមកបិទមាត់,ច្រមុះជិតសំល្អមនៅពេលដែលក្អក ម្យ៉ាងទៀតសូមកំភ្លេចប្រាប់អ្នកដ៏ទៃអោយធ្វើដូចអញ្ចឹងផង។ ក្រៅពីការពាររោគរបេងហើយ ព្រមទាំងជួយការពាររោគផ្សេងៗបន្តាលមកពីការដកដង្ហើម ដូចជា ផ្តាសាយ ជាដើម។
- ➢ តាមគេហ:ស្ថានត្រូវតែមានអាកាសធាតុចេញចូលបានល្អ និងមានកំដៅថ្ងៃៗអាចជួយធ្វើអោយសម្លាប់មេរោគបានល្អ គួរតែយកកន្ទេល,ពូក,ភួយ,ខ្នើយមកហាលថ្ងៃជារៀងរាល់ពេល។
- ➢ មេរោគរបេងវាអាចរស់នៅបានយូរច្រើនឆ្នាំ កន្លែងណាដែលស្អុក ងងឹត និងមិនមានអាកាសធាតុ ដូច្នេះគួរតែជៀសវាងកន្លែងទាំងអស់នោះ ដូចជា រោងភាពយន្ត តាមការាអូខេ ជាដើម។
- ➢ បញ្ឈប់ជក់បារី គ្រឿងស្រវឹង គ្រឿងញៀន ពិព្រោះវត្ថុទាំងអស់នេះវាធ្វើអន្តរាយ, បំផ្លាញដល់សុខភាព ធ្វើអោយរាងកាយចុះអន់ខ្សោយ ឆ្លងមេរោគបានងាយស្រួល ឈឺស្កាត់បានងាយ។
- ➢ បើសិនមានក្អករីងរៃយូរ ២-៣ អាទិត្យ ឬក្អកមានឈាមជាប់មកជាមួយស្លេះ ត្រូវព្រឹក្សាជាមួយនិងអ្នកជំនាញមណ្ឌលសុខភាព ឬគ្រូពេទ្យ សូមកុំទិញថ្នាំមកលេបខ្លួនឯង ឬយកថ្នាំអ្នកដ៏ទៃមកលេបសាកល្បង។
- ➢ លោកអ្នកគួរតែយល់ថា អ្នកជំងឺរបេងដែលលេបថ្នាំលើសពី ៣ អាទិត្យហើយ ក្អកវាក៏បានចុះអន់ដែរ វាក៏មិនអាចចំឡងឆ្លងមេរោគរបេងទៅអ្នកដ៏ទៃបានតិចដែរ លោកអ្នកទើបមិនគួរអោយខ្ពើមរអើមដល់អ្នកដែលមានរោគរបេងកំពុងតែថែរក្សានោះឡើយ។

# ក្អកត្រូវតាមក្បួន និងបានល្អដល់លោកអ្នក

## នៅពេលដែលក្អក លោកអ្នកត្រូវចងចាំទុកក្នុងជានិច្ច។



ក្អកបែបនេះ វាអាចសង្ហាប៉ុន្តែវាមិនមានក្តីភាព បើសិនលោកអ្នកក្អកមក មានមេរោគ មេរោគទាំងនេះវានិងអាចចំឡងបាន លោកអ្នកសាងបាប ដោយមិនដឹងខ្លួន។



ក្អកបែបនេះ បិទមាត់,ច្រមុះដោយត្រឹមត្រូវ មានសុវត្ថិភាពមិនយកមេរោគទៅចំឡងអ្នកដ៏ទៃ។

# នេះគឺជាបទពិសោធ ! មេរោគរបេងនិងមេរោគអេដស៍ វាមិនបានឆ្លងតាមការស្រស់ស្រូបអាហាររួមគ្នានោះទេ



ក្រុមវេជ្ជៈបណ្ឌិតនិងបុគ្គលិកពេទ្យ ព្រមទាំងអ្នកគ្រូពេទ្យសុជានី អ្នកគ្រូពេទ្យណាន់ថៈណា វេជ្ជៈបណ្ឌិតធូតិផង្ស និងបុគ្គលិកពេទ្យវិជាផន នៃមន្ទីពេទ្យម៉ែចាន់ កំពុងអង្គុយជុំគ្នាស្រស់ស្រូបអាហារជាមួយនិងអាសាស្ម័គ្រចិត្តអ្នកជំងឺអេដស៍ និងរោគរបេង ដើម្បីធ្វើបទពិសោធអោយឃើញច្បាស់ថា អ្នកជំងឺបានលេបថ្នាំដោយក្រឹតក្រំត្រង់តាមពេលវេលា ៣អាទិត្យឡើងទៅហើយក្អកវាអន់ថយចុះ មិនអាចឆ្លងមេរោគទៅអោយអ្នកដ៏ទៃបានឡើយ ដូច្នេះលោកអ្នកសូមកុំខ្មើមរអើម លោកអ្នកអាចពិសារបាយរួមគ្នាបាន។

គ្រូពេទ្យប្រាប់ថា មេរោគអេដស៍ និងមេរោគរបេងមិនបានឆ្លងដោយសារតែពិសារបាយរួមគ្នានោះទេ។ ក៏ប៉ុន្តែមានមេរោគជាច្រើនទៀតឆ្លងតាមទឹកមាត់បាន ដូចជា ដំបៅមាត់ ពងបែកក្នុងមាត់ ដូច្នេះពេលពិសារបាយរួមគ្នា គ្រប់ៗគ្នាត្រូវតែមានស្លាបព្រារបស់ខ្លួនឯង ហើយនិងត្រូវប្រើស្លាបព្រាកន្តាល និងចានតូចសំរាប់ដួសសម្លរផងដែរ។

# តើកើតអ្វី ?

## នៅពេលមេរោគរបេងឆ្លងចូល ទៅក្នុងរាងកាយរបស់យើង!!!



មនុស្សធម្មតាដែលមិន
មានមេរោគរបេង

ដកដង្ហើមស្រូបយកខ្យល់
អាកាសដែលមានរោគរបេង

រាងកាយឆ្លងមេរោគរបេង



បើសិនរាងកាយ
មានប្រព័ន្ធល្អ។

ខ្លួនរបស់គេ "ជាអ្នកឆ្លងមេរោគរបេង" គឺ

- មេរោគរបេងត្រូវរារាំងមិនអោយបញ្ចេញឥទ្ធិពលបានត្រឹមតែលួចរែបសង្ងំក្នុងរាងកាយ មិនបានធ្វើអោយរាងកាយឈឺស្កាត់។
- មិនបានធ្វើអោយរាងកាយឈឺស្កាត់។
- ចំឡងមេរោគទៅអោយអ្នកដ៏ទៃមិនបាន។
- បើសិនទទួលទានថ្នាំការពាររោគរបេង (ថ្នាំ ១ ប្រភេទ លេបរយៈពេល ៩ខែ) ក៏បន្ថយការឈឺស្កាត់រោគរបេងបាន។



បើសិនរាងកាយ
មានប្រព័ន្ធមិនល្អ។

ខ្លួនរបស់គេ "ជាអ្នកឆ្លងមេរោគរបេង" គឺ

- ពេលឈឺស្កាត់និងអាចចំឡងមេរោគរបេងទៅអោយអ្នកដ៏ទៃបានបើសិនមិនរក្សាព្យាបាល។
- បើសិនទទួលទានថ្នាំបានត្រឹមត្រូវ (ថ្នាំ ៤ប្រភេទ លេប ៦ខែឡើងទៅ) ទើបនិងអាចជាសះស្បើយបាន។
- អ្នកជំងឺដែលទទួលទានថ្នាំរោគរបេង ៣ អាទិត្យឡើងទៅ ថ្នាំនិងធ្វើចលនាប្រយុទ្ធសម្លាប់និងមេរោគរបេងមិនអោយចំឡងទៅអ្នកដ៏ទៃបាន។



រាងកាយមិនឆ្លងរោគរបេង




# ធ្វើបែបនេះ ទើបមិនភ្លេចទទួលទានថ្នាំ!

បញ្ហារបស់អ្នកជំងឺរោគរបេង គឺត្រូវតែលេបថ្នាំអោយបានគ្រប់គ្រាន់និងបន្តបន្ទាប់ជាប់ជានិច្ចអោយបាន ៦ខែឡើងទៅ។ វិធីដែលល្អបំផុតដើម្បីការពារកុំអោយភ្លេចលេបថ្នាំ គឺត្រូវតែមានអ្នកចាំដាស់តឿន ចាំឃ្លាំមើលអោយអ្នកជំងឺលេបថ្នាំជារៀងរាល់ថ្ងៃ វិធីការពារដែលអ្នកជំងឺភ្លេចលេបថ្នាំ បើសិនធ្វើមិនបាន ។ អ្នកជំងឺជាច្រើននាក់ទៀត ប្រើតាមលទ្ធិផលនេះបានល្អ គឺទុកដាក់កន្លែងថ្នាំអោយជិតនិងរហ័សមើលឃើញ។ ហើយក្រឡែកមើលឃើញរាល់ថ្ងៃ ដូចជា លើតុហូបបាយ លើទូរទស្សន៍ លើទូទឹកកក ទូខោអាវ លើតុដាក់មាកយេ ឬដាក់ក្នុងផ្ទប់សំរាប់ដាក់ថ្នាំ។





# ជីវិតនៅមានក្តីសង្ឃឹម បើនៅមានកំលាំងចិត្ត !

អ្នកខ្លះអាចមិនជឿថា មានចំណេះនិងមានការយល់ដឹងដែលត្រឹមត្រូវទាក់ទងនិងរោគរបេងនិងរោគអេដស៍ អាចជួយជីវិតអ្នកជំងឺរោគរបេងអោយផុតពីក្តីអស់សង្ឃឹម និងការឈឺចាប់អំពីការឈឺស្កាត់បានពិតមែន រឿងដែលលោកអ្នកនិងបានអានបន្តទៅទៀត គឺជារឿងពិតទាំងអស់ (លើកលែងតែឈ្មោះដែលយកមកឧទាហរណ៍ជំនួសពីរឿងពិត ដើម្បីធ្វើអោយសំរម្យក្នុងការផ្សព្វផ្សាយ) អ្នកជំងឺទាំងអស់នេះក្រោពីការឈឺស្កាត់បន្តាលមកពីរោគរបេងហើយ ក៏នៅមានឆ្លងរោគអេដស៍ផងដែរ ច្រើននាក់ទៀតមានរោគផ្សេងៗមកបញ្ចៀតធ្វើអោយឈឺស្កាត់កាន់តែបន្ថែមទៀត។ នេះជារឿងធ្វើអោយជាប់ចិត្ត សម័យមុននៅមិនទាន់មានថ្នាំជួយបង្ការការពារនិងមេរោគវីរុសអេដស៍ដូចសម័យនេះទេ និងមានអ្នកជំងឺជាច្រើននាក់ទៀតក៏មិនមានការងារធ្វើ អ្នកជំងឺខ្លះត្រូវអោយរស់នៅម្នាក់ឯង ហេតុអីបានអ្នកជំងឺទាំងអស់នេះអាចយកឈ្នះរោគរបេងបាន។

អ្នករៀបចំបោះពុម្ពសូមថ្លែងអំណរអរគុណអ្នកជំងឺទាំង ៦ នាក់ ដែលអនុញ្ញាតនាំយករឿងដ៏ពិតប្រាកដនិងរូបភាពមកផ្សព្វផ្សាយ ដើម្បីអោយមានក្តីសង្ឃឹមនិងមានកំលាំងចិត្តដល់អ្នកកំពុងតែមានក្តីអស់សង្ឃឹម មានក្តីឈឺចាប់ ដូចពួកយើងខ្ញុំដែលធ្លាប់មានការឈឺចាប់មកពីមុនដែរ។

**"ជីវិតនៅមានក្តីសង្ឃឹម បើនៅមានកំលាំងចិត្ត !"**

# និតយ៉ា... ពិបាកប៉ុនណាចិត្តក៏មិនដែលព្រមចុះចាញ់ យកចិត្តទុកដាក់លេបថ្នាំ ដើម្បីរស់នៅថែរក្សាកូន !



នៅមិនទាន់បានថែរក្សា



ក្រោយពីបានថែរក្សាហើយ

**នាងនិតយ៉ា (ជាឈ្មោះសន្មត់) អាយុ ២៨ឆ្នាំ**

និតយ៉ាឆ្លងមេរោគអេដស៍មកពីប្តីបានស្លាប់ទៅហើយរយៈពេល ៥ឆ្នាំ ចោលអោយនាងនិងកូនពីរនាក់ទៀតចិញ្ចឹមជីវិតរស់នៅដោយឯការ នាងបានត្រឡប់ទៅផ្ទះរស់នៅជាមួយឳពុកម្តាយនិងកូនស្រី ផ្នែកឯកូនប្រុសបានប្រគល់ឱ្យបងប្អូនខាងប្តីចិញ្ចឹមថែរក្សា នាងបានចាប់ផ្តើមឈឺ អស់កំលាំង នឿយហត់ និងក្អកពិបាកក្នុងខ្លួនទើបដេកមិនបាន។ នាងក៏បានទៅមន្ទីពេទ្យត្រួតពិនិត្យរោគក៏បានឃើញថានាងមានរោគស្ទូត នាងតាំងចិត្តថាត្រូវតែថែរក្សាអោយជាដាច់ក្រោពីការលេបថ្នាំរក្សារោគរបេងបានប្រហែលជា ២-៤ អាទិត្យ ក្អកក៏បានថូ មិនសូវពិបាកដូចដើម ហើយមិនមានអាការៈនឿយហត់ នាងបាននិយាយថាខ្ញុំតាំងចិត្តលេបថ្នាំប្រយ័ត្នមិនអោយភ្លេច កំពុងនៅថែរក្សាឯមន្ទីពេទ្យ នាងឃើញអ្នកជំងឺរោគរបេងម្នាក់ត្រូវបានចាក់ថ្នាំជារៀងរាល់ថ្ងៃ លោកគ្រូពេទ្យប្រាប់ថា បើសិនលេបថ្នាំមិនបានបន្តបន្ទាប់ជារៀងរហូតមេរោគអាចមកទប់ទល់និងថ្នាំបានវិញ។

បានត្រូវចាប់ផ្តើមថែរក្សាជាថ្មីនិងមានការចាក់ថ្នាំផងដែរ។

និតយ៉ាជាគំរូអោយដល់របស់អ្នកឆ្លងជំងឺអេដស៍និងជំងឺរោគរបេង នាងបានអត់ទ្រាំអត់ធ្មត់តស៊ូជាមួយរោគរបេងដោយពេញទំហឹងដោយមិនព្រួយបារម្ភអ្វីទាំងអស់ យកចិត្តទុកដាក់លេបថ្នាំដោយមិនភ្លាចនឿយហត់ ពិបាក ជាពិសេសនាងមានមេរោគវីរុសដំបៅពងបែកក្នុងមាត់គ្រាន់តែហូបទឹកក៏ពិបាក មានពេលខ្លះលេបថ្នាំក៏មិនបានដែរ កិនថ្នាំអោយម៉ត់នៅតែលេបមិនបាន នាងក៏អត់ទ្រាំលេបក្នុងខែទី ៤-៥ ដែលកំពុងតែលេបថ្នាំនាងមានអាការៈឈឺក្បាល ក្អួតចង្អោជាញឹកញាប់ លេបថ្នាំចូលទៅក៏ក្អួតចង្អោចេញមកវិញអស់ ត្រូវលេបជាថ្មី នាងក៏មិនឈប់លេប ហើយនាងកត់ត្រាទុកក្នុងកូនសៀវភៅ ដើម្បីមិនអោយច្រឡូកច្របល់។

នាងទាំងក្អួតចង្អោទាំងឈឺមាត់ហើយលេបថ្នាំមិនត្រង់ពេលវេលា ឬក៏ហូបមិនបាន នាងក៏កត់ត្រាទុកដាក់ក្នុងកូនសៀវភៅជារៀងរហូត ដើម្បីលេបជាសាថ្មីអោយបានគ្រប់។

មានថ្ងៃមួយនិតយ៉ាឈឺកាន់តែខ្លាំងបន្ទាលមកពីរោគឱកាសនិយមផ្សេងៗ គឺមេរោគវីរុសឡើងខួក្បាល ហើយឈឺក្បាលខ្លាំង ធ្វើអោយប្រកាច់ ភ្នែកស្ទើឡើងសរ ធ្វើអោយមិនដឹងខ្លួន ពេលនោះឯងនាងខ្ញុំគិតថាប្រហែលជាមិនរស់ទៅហើយ នៅទីបំផុតនាងក៏ជាឡើងវិញ ហើយនាងក៏តាំងចិត្តទប់ទល់តស៊ូនិងជីវិតនិងថែរក្សារោគផ្សេងៗ ទើបរោគរបេងក៏បានជាសះស្បើយ និងការឈឺស្កាត់ផ្សេងៗក៏បានគ្រាន់បើឡើងវិញ ហើយក៏បានជួយខ្លួនឯងឡើងវិញបាន នាងប្រាប់ថាមេរោ គរបេងរក្សាបាន នាងខ្ញុំចង់ជាគំរូអោយដល់អ្នកជំងឺដែលបានថែរក្សាបាត់ហើយ និងជាកំលាំងចិត្តគ្រប់ៗគ្នា។

# សុជា..."ទទួលទានថ្នាំម្តងៗត្រូវប្រើពេលវេលាមួយម៉ោងឡើងទៅ ទោះបីយ៉ាងណាក៏ទ្រាំដើម្បីអោយមានសុវត្ថិភាពដល់អ្នកដែលយើងស្រឡាញ់"



**នាងសុជា (ជាឈ្មោះសន្មត់) អាយុ ៣៨ឆ្នាំ**



ក្រោយពីបានថែរក្សាហើយ

នាងជាស្ត្រីម្នាក់ទៀតដែលបានគ្រោះថ្នាក់គឺឆ្លងជំងឺអេដស៍និងរោគរបេងពីប្តី នៅពេលប្តីបានស្លាប់ នាងក៏ត្រឡប់ទៅនៅស្រុកកំណើតវិញជាមួយឪពុកម្តាយរបស់នាង ហើយនៅថ្ងៃមួយ នាងក៏បានឈឺធ្ងន់ទើបទៅរក្សានៅឯមន្ទីរពេទ្យបាន ៤-៣ ថ្ងៃ លោកគ្រូពេទ្យក៏ប្រាប់ថា នាងបានត្រូវរោគរបេងនិងរោគឱកាសនិយមចូលមកធ្វើសកម្មភាពនៅក្នុងរាងកាយរបស់នាងដែលអន់ខ្សោយបន្ទាលមកពីឆ្លងមេរោគអេដស៍ ប៉ុន្តែលោកគ្រូពេទ្យក៏ប្រាប់ដល់នាងថា រោគរបេងសូតថែរក្សាជាដាច់បានមិនថ្វីទេ។ ពិព្រោះថានិងជួយអោយនាងជាសះស្បើយនិងបំបាត់ការឈឺចាប់ពីរោគផ្សេងៗ បានដូចជា ក្អក ខ្លាំង ឡើយហត់ ពិបាកដកដង្ហើម ជាពិសេសនិងជួយការពារមិនអោយអ្នកជិតខាងឆ្លងរោគរបេងពីនាងបានផងដែរ។

សុជានិយាយថា នាងខ្ញុំបានកាត់ចិត្តថែរក្សាហើយ ក៏មិនដែលគិតថាផ្លាស់ប្តូរចិត្តដែរ កំពុងដែលចាប់ផ្តើមលេបថ្នាំថ្មីៗត្រូវប្រើពេលវេលាទម្រាំនិងបានលេបថ្នាំអោយគ្រប់ចំនួនក្នុងមួយថ្ងៃៗ "នៅពេលនោះមេរោគវីរុសនិងមេរោគដំបៅពងបែកនៅក្នុងមាត់និងកករ នាងខ្ញុំដឹងថាអស់កំលាំង ខ្សោយ ហូបបាយមិនបាន ហើយក្អកធ្វើអោយនាងខ្ញុំចង់ដាច់ដង្ហើមម្តងៗ ប៉ុន្តែពិបាកយ៉ាងណាក៏ត្រូវលេបថ្នាំអោយគ្រប់តាមចំនួនក្នុងមួយថ្ងៃៗ ម៉ែជួយផ្តល់កំលាំងចិត្តនិងជួយចាំដាស់តឿននាងខ្ញុំដឹងថាត្រូវលេបថ្នាំជារៀងរាល់ថ្ងៃអោយគ្រប់ ៦ ខែទើបនិងជាដាច់។ តែនាងសុជាក៏ទ្រាំអត់ធ្មត់តាំងចិត្តលេបថ្នាំអោយគ្រប់ចំនួនមិនដែលខានមិនដែលភ្លេច ទើបនាងបានកាន់តែជាស្បើយឡើងវិញ ម្យ៉ាងទៀតនាងក៏ជាពីរោគរបេងមានសុខភាពមាំមួន។ មានកំលាំងធ្វើការបានដូចដើម ទម្ងន់ឡើងស្រើតៗពី ៣៣ គីឡូ ឡើងទៅ ៣៩ គីឡូ កាលពីអាការៈបានចាប់ផ្តើមល្អ នាងពិសារបាយបានសំរានក៏បានមិនពិបាកឈឺចាប់បន្តទៅទៀត។

នាងប្រាប់ថា ការដែលតាំងចិត្តលេបថ្នាំអោយគ្រប់ចំនួន "ក៏ព្រោះតែស្រឡាញ់ឪពុកម្តាយ។ លោកគ្រូពេទ្យប្រាប់ថាបើសិនលេបថ្នាំរក្សាក៏មិនចំឡងមេរោគអោយដល់ឪពុកម្តាយ ហើយនាងក៏បានតាំងចិត្តលេបថ្នាំ ព្រោះនាងមានការព្រួយបារម្ភមិនចង់អោយឪពុកម្តាយនិងអ្នកជំទែមកឆ្លងរោគរបេងពីនាងខ្ញុំ នាងខ្ញុំឈឺតែម្នាក់ឯងវាក៏ពិបាកហើយ"។ ស្រឡាញ់ឪពុកម្តាយ ត្រូវតែថែរក្សាខ្លួនឯង។

# ស្មោះ... ក្រោកឈរបានទៀត គាត់គិតថាត្រូវតែតស៊ូ !



នៅមិនទាន់បានរក្សា



បន្ទាប់ពីរក្សាហើយ

## លោកស្មោះ (ជាឈ្មោះសន្មត់) អាយុ ៣៤ឆ្នាំ

ស្មោះលោកជាពោះម៉ាយ គាត់ជាមនុស្សម្នាក់ទៀតដែលឆ្លងមេរោគអេដស៍ហើយក៏ឈឺបានចូលទៅមន្ទីពេទ្យ គាត់បានហត់ ក្អក អស់កំលាំង ថែរក្សានៅមិនទាន់បានជាសះស្បើយផង គាត់ក៏ត្រឡប់ទៅផ្ទះមុនបន្តមកខាងមន្ទីពេទ្យត្រួតពិនិត្យគាត់សាជាថ្មីក៏ជួបប្រទះឃើញគាត់មានរោគរបេងសួត។ បុគ្គលិកពេទ្យយកថ្នាំមកថែរក្សារោគរបេងអោយគាត់នៅឯផ្ទះ បានជួយណែនាំអោយគាត់លេបថ្នាំ គាត់លេបថ្នាំបានមួយគ្រាស្មោះក៏ព្រត្តិកម្មថ្នាំ (ចាញ់ថ្នាំលេបហើយចេញកន្ទួល) ស្មោះលោកគិតថាគាត់និងឈប់លេបថ្នាំ ព្រោះដឹងថាលេបបន្តទៅទៀតមិនបាន សពាង្គកាយទន់ខ្សោយខ្លាំងក្អួតរហូត ទើបហូបអ្វីមិនបានទាល់តែសោះ។

គាត់និយាយថា"ពេលនោះឯង ដឹងខ្លួនថាមិនមានកំលាំង អស់សង្ឃឹមក្រោកមិនរួច មិនចង់ក្រោកគិតតែចង់ស្លាប់ ព្រោះគិតថានៅលើខ្លួនខ្ញុំមានទាំងជំងឺរបេងមានទាំងជំងឺអេដស៍"។

ប៉ុន្តែខ្ញុំបាតមានសំណាងល្អដែលខាងមន្ទីពេទ្យមកសួរសុខទុក្ខដល់ផ្ទះបានជួយណែនាំឪពុកនិងបងស្រីរបស់ខ្ញុំបានអធិបាយជួយពន្យល់អោយយល់ដល់រោគរបេងគឺជារោគមិនមែនជាគ្រោះថ្នាក់ប៉ុន្មានអាចថែរក្សាជាដាច់បានមិនតែប៉ុណ្ណោះមេរោគអេដស៍ក៏មិនមែនជារោគដែលអស់សង្ឃឹមដែរបើសិនលោកអ្នកអត់ធ្មត់លេបជាបន្តទៅទៀតប្រការសំខាន់គឺ លេបថ្នាំថែរក្សារោគរបេងជួយការពារមិនអោយឆ្លងទៅអ្នកដ៏ទៃនិងអ្នកជិតខាង,អ្នកជួយចាំថែរក្សាដើម្បីមិនអោយគ្រោះថ្នាក់ការឆ្លងរោគរបេងពីគាត់ផងដែរ ពេលលោកស្មោះបានស្តាប់ហើយ បានកាត់ចិត្តនិងតស៊ូលេបថ្នាំបន្តក្រុមគ្រួសារជួយចាំថែរក្សាក្នុងការលេបថ្នាំអោយគ្រប់ចំនួន និងបានបន្តបន្ទាប់។

ហើយស្មោះគិតថាគាត់បានកាត់ចិត្តមិនខុសក្តីបំណងឡើយ នៅពេលអត់ធ្មត់លេបថ្នាំអោយគ្រប់តាមចំនួន ៦ ខែ នៅទីបំផុតស្មោះក៏បានជាពីមេរោគរបេងឥឡូវនេះគាត់មានសុខភាពមាំមួន គ្មានអ្នកណាជឿថាគាត់និងអាចក្រោកឡើងបាន។ ថែមទាំងបើករថយន្តកង់បីរកស៊ីចិញ្ចឹមជីវិតនិងក្រុមគ្រួសារបាន ម្យ៉ាងទៀតគាត់បានជួយដល់អ្នកដែលជារោគរបេងដ៏ទៃៗទៀតអោយទៅរក្សានៅឯមន្ទីពេទ្យដើម្បីអោយបានជាសះស្បើយដូចគាត់ផងដែរ។



# កុមារី ផាន់ធិដា... ជាក្មេងកំព្រាមិនរាថយ ទោះបីម្នាក់ឯង ក៏មិនរុញរាដែរ !



រូបភាពបច្ចុប្បន្ន

## កុមារី ផាន់ធិដា (ជាឈ្មោះសន្មត់) អាយុ ១១ឆ្នាំ

ផាន់ធិដា ជាក្មេងស្រីអភព្វឪពុកម្តាយបានស្លាប់ចោលនាងទៅហើយ បន្ទាលមកពីឆ្លងមេរោគអេដស៍ នាងក៏ឆ្លងមេរោគអេដស៍ដែរហើយក៏បានរស់នៅជាមួយបងប្អូនខាងឪពុក អោយនាងរស់នៅជាមួយក្រុមគ្រួសារដោយមិនស្តាប់ខ្ពើម ក្រោយមកផាន់ធិដានាងក៏ចាប់ផ្តើមឈឺ មានគ្រុនជាញឹកញាប់ អស់កំលាំងផុញនិងអាហារ មានចេញសញ្ញាអុចៗតាមខ្លួនកើតហើយបាត់ៗច្រើនថ្ងៃខែ នាងទើបទៅត្រួតរក្សានៅឯមន្ទីរពេទ្យប្រចាំខេត្ត។ លោកគ្រូពេទ្យប្រាប់ថា ផាន់ធិដានាងឈឺជំងឺរោគរបេង ធ្វើអោយញាតិដែលរស់នៅជាមួយក្លាយឆ្លងរោគរបេងពីនាង ទើបធ្វើខ្ទមតូចមួយអោយនាងនៅម្នាក់ឯង ថែមទាំងអោយនាងហូបបាយម្នាក់ឯងទៀត។

ហើយនាងទើបដឹងតូចចិត្តខ្លួនឯងត្រូវរស់នៅឈឺតែម្នាក់ឯង ហើយក្មេងស្រីអាយុ ១១ឆ្នាំម្នាក់នេះ បែរជាមិនដកថយ មិនរុញរានិងវាសនាជីវិត តាំងចិត្តថាត្រូវតែថែរក្សាខ្លួនឯងអោយជាពីរោគរបេងអោយបាន។ ពីព្រោះមិនចង់ចំឡងមេរោគទៅអោយអ្នកដទៃ នាងខ្ញុំជឿថាជីវិតនៅមានសង្ឃឹម "នាងខ្ញុំលេបថ្នាំរក្សារោគរបេងខ្លួនឯងជារៀងរាល់ថ្ងៃ មិនដែលភ្លេចលេបថ្នាំម្តងណាទេ។ លោកគ្រូពេទ្យប្រាប់ថា បើសិនលេបថ្នាំមិនបានជាប់និងធ្វើអោយមេរោគប្រឆាំងនិងថ្នាំបានវិញហើយរក្សាមិនជា។ នាងខ្ញុំបានដាស់តឿនខ្លួនឯងរាល់ថ្ងៃមានពេលខ្លះញាតិជួយចាំដាស់តឿនផងដែររឿងការលេបថ្នាំព្រោះថាចង់អោយខ្លួនឯងបាត់ពីរោគទាំងអស់នេះ លោកគ្រូពេទ្យប្រាប់ថាបើសិនអ្នកជំងឺអេដស៍ថែទាំខ្លួនឯងបានល្អរក្សារោគឱកាសនិយមផ្សេងៗ អោយជាដាច់ យើងក៏មានជីវិតរស់នៅបានយូរដែរ នាងខ្ញុំជឿហើយខ្ញុំបានឃើញបងៗនៅក្នុងភូមិគាត់មានកំលាំងមាំមួន។
លោកគ្រូពេទ្យប្រាប់ថា រោគរបេងក៏រក្សាជាដាច់បានបើសិនលេបថ្នាំអោយគ្រប់ចំនួន ៦ ខែ"។

ពេលនាងផាន់ធិដាលេបថ្នាំរក្សារោគរបេងបាន ៣ ខែកន្លងទៅ នាងក៏បានទទួលថ្នាំការពាររក្សាមេរោគវីរុសអេដស៍ផងដែរ មុនដំបូងនាងបានប្រតិកម្មថ្នាំជាមួយនិងថ្នាំការពារ នាងក៏ឈឺពោះយ៉ាងខ្លាំង ក្អួត នៅពេលរាងកាយមានសភាពដូចដើមហើយ រោគផ្សេងៗក៏បានគ្រាន់បើដែរ នាងទើបលេបថ្នាំរក្សារោគរបេងព្រមទាំងថ្នាំការពារមេរោគអេដស៍ សព្វថ្ងៃនេះផាន់ធិដាជាកុមារីមានរូបរាងស្គមហើយតូច ប៉ុន្តែនាងមានសុខភាពមាំមួន មុខស្រស់បពោះ និយាយស្តីសើចសប្បាយតាមវ័យរបស់នាង ញាតិដែលថែទាំរក្សានាងបច្ចុប្បន្នពួកគាត់ក៏យល់ត្រឹមត្រូវទាក់ទងនិងរោគទាំងអស់នោះ មិនបាច់ភ្លាចឆ្លងរោគរបេងចេញពីអ្នកជំងឺដែលបានលេបថ្នាំរក្សារោគរបេងត្រឹមត្រូវដោយក្រិតក្រំ ក្រោយពីបានលេបថ្នាំរយៈពេល ៣ អាទិត្យ ថ្នាំក៏ទៅធ្វើសកម្មភាពរារាំងប្រយុទ្ធប្រឆាំងមិនអោយមេរោគទៅចំឡងដល់អ្នកដទៃទៀត។ ដូច្នេះអ្នកជំងឺអាចហូបបាយនិងរស់នៅជាមួយនិងអ្នកដទៃបាន។

# លោកឈូឆ័យ... គិតថាដូចជាប់គុក ៦ ខែ !



នៅមិនទាន់ថែរក្សា



បន្ទាប់ពីរក្សាហើយ

## លោកឈូឆ័យ (ជាឈ្មោះសន្មត់) អាយុ ៣៤ឆ្នាំ

មុនដំបូងញាតិរបស់ឈូឆ័យបាននាំគាត់ទៅមន្ទីពេទ្យ គ្រប់ៗគ្នាថាគាត់ប្រហែលជា"មិនរស់ទេ" មើរទៅ ពិព្រោះគាត់ឈឺធ្ងន់ហើយ មានជំងឺហត់ក្អក និងខ្សោយអស់កំលាំង លោកគ្រូពេទ្យប្រាប់ថា គាត់បានឈឺជំងឺរោគរបេងសួត ពិសេសជាងនោះទៅទៀតគ្រូពេទ្យបានត្រួតពិនិត្យឈាមប្រទះឃើញថាឈូឆ័យឆ្លងជំងឺអេដស៍តាំងតែពីយូរមកហើយ។ ទោះបីយ៉ាងណាក៏ដោយ គាត់នៅតែសំរេចចិត្តថានៅតែរក្សារោគរបេង គាត់មិនគិតថាឆ្លងមេរោគអេដស៍ហើយថែរក្សាទៅធ្វើអ្វី គាត់បានជឿថាឆ្លងអេដស៍ក៏នៅតែមានក្តីសង្ឃឹម ច្រើនឆ្នាំមុននៅមិនទាន់មានថ្នាំពន្យាពេលដូចសម័យបច្ចុប្បន្នគាត់ក៏មិនដកថយរុញរា ជីវិតត្រូវតែតស៊ូ។

ឈូឆ័យត្រឡប់មកផ្ទះព្រមទាំងថ្នាំសំរាប់រក្សារោគរបេង គ្រូពេទ្យបានផ្តាំផ្ញើថាកុំភ្លេចលេបថ្នាំ ហើយលេបអោយបានជាប់រាល់ថ្ងៃទោះបីជាប្រើពេលវេលាយូរក៏ដោយ ជំងឺវានិងត្រឡប់ធ្វើអោយជាសះស្បើយពីការឈឺចាប់ដោយសារតែរោគរបេងវិញមិនខាន។

ពុំន្តែឈូឆ័យគាត់បានគិតហើយថាការលេបថ្នាំមិនមែនជារឿងធម្មតា ក្រោយពីការលេបថ្នាំរក្សារោគរបេងបានមួយរយៈគាត់ក៏ប្រតិកម្មថ្នាំ ភ្នែកឡើងលឿង ក្អករហូតដល់ហូបបាយមិនបាន ទើបដឹងខ្លួនឯងថារាងកាយចុះខ្សោយ មិនមានកំលាំង គ្រូពេទ្យប្រាប់អោយគាត់បញ្ឈប់លេបថ្នាំមួយរយៈប្រហែលជា ១០ ថ្ងៃ ក្រោយពីការឈប់លេបមកជំងឺក៏បានគ្រាន់បើឡើងវិញ ហើយក៏ឈប់ក្អក គាត់ត្រូវតែចាប់ផ្តើមលេបថ្នាំឡើងវិញព្រោះឈប់យូរមិនបានទេ មេរោគវានិងវិលត្រឡប់មកប្រឆាំងនិងថ្នាំបានវិញ គាត់លេបថ្នាំហើយដឹងខ្លួនថានៅតែមិនមានកំលាំង ហើយរោគរមាស់ក៏ចេញឡើងតាមខ្លួន កើតមកយ៉ាងនេះជាញឹកញាប់ ប៉ុន្តែគាត់អត់ធន់។

ឈូឆ័យនិយាយថា "ធ្លាប់គិតរុញរាដូចគ្នា ព្រោះថាពេលនោះឯងទាំងឈឺចាប់ទាំងពិបាកគិតថាខ្លួនឯងមិនរស់ទៅហើយ ជាពិសេសត្រូវតែលេបថ្នាំបន្តទៅទៀត ៦ ខែ ហើយភ្លេចក៏មិនបាន ខ្វះក៏មិនបាន។ ប៉ុន្តែញាតិៗនិងពួកមាកជួយផ្តល់កំលាំងចិត្ត ប្រាប់ថាយើងត្រូវគិតអោយដូចជាប់គុក ៦ ខែទៅចុះ គាត់មានកំលាំងចិត្តទើបមិនព្រមចុះចាញ់ក្នុងការលេបថ្នាំ ហើយរាងកាយក៏បានមានកំលាំងឡើងវិញជាសន្សឹមៗ ទម្ងន់ក៏ឡើង កំពុងចាប់ផ្តើមរក្សាមានទម្ងន់តែ ៤០ គីឡូ ពេលជំងឺបានជាសះស្បើយពីរោគរបេងគាត់មានទម្ងន់ឡើងធ្ងន់លើសដើម បានទៅដល់ ៤៥គីឡូហើយ ទម្ងន់របស់គាតធ្លាប់ឡើងបំផុតដល់ ៤៧ គីឡូ ធ្វើអោយសុខភាពមាំទាំផងដែរ។

# អាំផន... មិនគិតច្រើនគិតតែចង់ជាម្យ៉ាងគត់ !



នៅមិនទាន់ថែរក្សា





បន្ទាប់ពីរក្សាហើយ

## នាងអាំផន (ជាឈ្មោះសន្មត់) អាយុ ២៩ឆ្នាំ

អាំផនជាអ្នកមកពីខាងទិសឦសាន(ឈាងម៉ៃ ឈាងរាយ) បន្ទាប់មកនាងក៏បានទៅរស់នៅជាមួយស្វាមីដែលជាមុខរបរអ្នកនេសាទនៅឯខេត្តឈុំផន នាងក៏ឆ្លងអេដស៍ពីប្តី ហើយនៅថ្ងៃមួយនាងបានជូនដំណឹងប្រាប់ដល់ម្តាយរបស់នាងថាឥឡូវនេះខ្ញុំបានឈឺធ្ងន់ ខ្ញុំចង់ត្រឡប់មកផ្ទះវិញប៉ុន្តែមិនមានលុយធ្វើដំណើរ បានពួអញ្ចឹងម្តាយរបស់នាងក៏ផ្ញើលុយមកអោយ នៅពេលត្រឡប់ដល់ផ្ទះម្តាយរបស់នាងនាំទៅថែរក្សាឯមន្ទីពេទ្យក្នុងស្រុកមានជំងឺគ្រុន ក្អក ញៀយហត់ អស់កំលាំង ទម្ងន់ស្រកចុះអស់ ៧ គីឡូ គ្រូពេទ្យបានការផ្លុះអិចសារេស្វត ហើយយកស្លេះទៅត្រួតពិនិត្យ ជួបប្រទះឃើញថានាងមានជំងឺរោគរបេងសួត។

អាំផននាងមានសំណាងល្អដែលនាងមិនសូវគិតច្រើន នាងប្រាប់ថាតាំងតែឆ្លងជំងឺអេដស៍ហើយនាងមិនខ្វល់ខ្វាយទោះបីអ្នកណាគិតមកលើរូបខ្ញុំល្អឬអាក្រក់ក៏ស្រេចតែពួកគេទៅចុះខ្ញុំគិតថាមិនមែនមានតែម្នាក់ឯងទេដែលឆ្លងជំងឺអេដស៍ ហើយឆ្លងអេដស៍ឬមិនឆ្លងអេដស៍ក៏ស្លាប់ដូចតែគ្នា។

ពេលដឹងថាអ្នកណាស្អប់ខ្ពើមហើយ នាងខ្ញុំក៏ឈប់ទៅទាក់ទងទៀត បើសិនអ្នកមានការយល់ដឹងរឿងជំងឺអេដស៍ដែលមិនភ្ញាចនិងនិយាយស្តីបាននៅដូចដើមក៏នៅតែមានប្រការការមិនគិតច្រើន ធ្វើអោយនាងមានអារម្មណ៍ ស្រស់ពោះ មិនវិលវល់ក្នុងខួក្បាល ទើបនិងមានសុខភាពល្អ។ នាងរក្សារោគរបេងតាមដែលលោកគ្រូពេទ្យបានណែនាំហើយលេបថ្នាំជាប់ជានិច្ច នាងមិនដែលភ្លេចហើយក៏មិនដែលគិតថានិងឈប់ផងដែរ។

នាងបាននិយាយថា "លេបថ្នាំរហូត គេអោយលេបក៏លេបមិនគិតអ្វីទាំងអស់ នាងខ្ញុំដាក់ចិត្តហើយធ្វើចិត្តហើយនៅលើលោកនេះគ្មានអ្វីទៀងទាត់ទេ ស្លាប់ដូចគ្នា"។ ខ្ញុំរៀងលេបថ្នាំមិនដែលគិតរុញរាចិត្ត,ភ្លាចបន្ទាប់ពីលេបថ្នាំរក្សាជំងឺរបេងហើយ ជំងឺផ្សេងៗដូចជា ហត់ញៀយ ក្អក គ្រុនតែឥឡូវនេះជាសះស្បើយបានទៅធ្វើធុរៈផ្សេងៗដូចពីមុនវិញបានហើយ។ មិនតែប៉ុណ្ណោះធ្វើការចិញ្ចឹមជីវិតខ្លួនឯងបានផងដែរ។

អាំផនជាអ្នកជំងឺដែលជាគំរូដល់បងៗប្អូនៗគ្រប់ៗគ្នា នាងបានឆ្លងជំងឺអេដស៍ហើយថែរក្សារោគរបេងដោយមានការតាំងចិត្តមិនអស់ក្តីសង្ឃឹម នាងបានគិតថានៅតែមានក្តីសង្ឃឹមនៅឡើយ។ ការអ្វីមួយបើយើងមិនខំប្រឹងក៏វាមិនបានសំរេច បើយើងនៅតែគិតថាគ្មានក្តីសង្ឃឹម។

**បើសិនលោកអ្នកជាមនុស្សម្នាក់ ធ្លាក់ក្នុងស្ថានភាពដូចជីវិតពួកគេទាំងអស់នោះ សូមលោកអ្នកពិចារណាតំរះគិតថា**

- ជីវិតនៅមានក្តីសង្ឃឹម បើសិននៅមានកំលាំងចិត្ត។
- ជំងឺរបេងថែរក្សាជាដាច់បាន បើសិនលោកអ្នកមានការយល់ដឹង និងការខំប្រឹងប្រែង។
- ជំងឺអេដស៍ជារោគរាំរ៉ៃ រក្សាជាមិនដាច់ ប៉ុន្តែមិនមែនត្រូវតែស្លាប់ម្យ៉ាងនោះទេ។

"សូមអោយលោកអ្នកមានតំរះការយល់ដឹង មានក្តីសង្ឃឹមនិងមានកំលាំងចិត្ត ខំតស៊ូជីវិតបន្តទៀតកុំរុញរាកុំដកថយ..."។

# សូមអរព្រះគុណ

អង្គការ, សហគម, បុគ្គលិក ទាំងអស់នេះជាអ្នកពិគ្រោះរឿង, រៀបចំនិងសម្រួលសម្រួលអត្ថន័យនិងន័យធ្វើអោយសំរេច

- អ្នកជំងឺ និងញាតិមិត្តដែលបានអនុញ្ញាតអោយយើងខ្ញុំសម្ភាសន៍អំពីរឿងរ៉ាវជីវិតដ៏ពិតប្រាកដប្រកបទៅដោយភាព ដោយចិត្តស្រលាញ់និងមានចិត្តបុណ្យ ដែលត្រូវការជួយអោយអ្នកជំងឺផ្សេងៗទៀតបានទទួលនូវអត្ថប្រយោជន៍និងធ្វើអោយមានកំលាំងចិត្តក្នុងការតស៊ូជាមួយនិងរោគរបេង។
- មូលនិធិការពារជំងឺអេដស៍នៃប្រទេសជប៉ុន (JFAP) ជួយឧបត្ថម្ភថវិកាបោះពុម្ព។
- លោកស្រីអរុណី ឆាយវិទ្យាផល្យ បណ្ឌិតបណ្ឌិតសាស្ត្រគ្រិស្ត មហាវិទ្យាល័យមនុស្សសាស្ត្រ ជាអ្នកពិគ្រោះរឿងដើម្បីផ្តល់សារៈប្រយោជន៍ដល់អ្នកជំងឺនិងសិស្ស និស្សិត ហើយអ្នកសិក្សាបានអានសៀវភៅនេះដែលបានយកចិត្តទុកដាក់ និងងាយយល់អត្ថន័យបានដោយងាយស្រួល។
- សាស្ត្រាចារ្យវេជ្ជបណ្ឌិត ជ័យយេត នុតព្រាក់ឃុន, លោកវេជ្ជបណ្ឌិត កំត់ នៅចំរះវិង, អ្នកស្រីវេជ្ជបណ្ឌិតជំនះវី នាត់តិផល្យ លោកវេជ្ជបណ្ឌិត ជ័រ ល្អូចាំងវិន, អ្នកស្រីវេជ្ជ ស៊ីព្រាក់ដា នេត្រធិយម, លោកវេជ្ជបណ្ឌិត បន្ទុំ សះវណ្ណបញ្ញាលើត Dr. Takashi Yoshiyama (RIT), Dr. Hideki Yanai (RIT) Dr. Norio Yamada (RIT) ជាអ្នកសម្រួលសម្រួលផ្នែកវិជ្ជាការ។
- លោកគម់នវ៉ាត់ វិរិយៈព្រាក់សុមធូក មកពីមន្ទីរពេទ្យលាងរាយប្រជាគុព្រះ ជាអ្នកសម្រួលសម្រួលផ្នែកខាងរឿងការពិសោធន៍របស់អ្នកជំងឺ។
- មកពីមន្ទីរពេទ្យម៉ែចាន់ សមាជិកជុំក្រុមអ្នកជំងឺអេដស៍ ជាអ្នកជួយផ្តល់ការណែនាំនិងជួយសម្រួលសម្រួលសេចក្តី។
- អ្នកស្រីពេទ្យសុផានី ចួណៈបេញផ្សៀន អ្នកស្រីពេទ្យនាត់ផាក់ណា ផាត់ផាក់ណាតិត្តិគុណ វេជ្ជបណ្ឌិតអូតិផល្យ ស៊ីរិភិទ្ធិគូះ មង្គល និងបុគ្គលិកពេទ្យវិកាដេង ជ័យនាម បានសំភាសន៍សំណាលនិងពិភាក្សាជាមួយអ្នកជំងឺអេដស៍និងជំងឺរបេង ដើម្បីជាមូលដ្ឋានការរៀបចំដាក់រឿងនិទានក្នុងសៀវភៅ។
- អ្នកស្រុកភូមិថាហោ ឃុំសាយខាវ ស្រុកថានៃ ខេត្តលាងពាយ ជាអ្នកសំរួះសំរួលអានដើមឡាប់ ដែលទាំងមូលមានពិភាក មុំយចំនួន ៣០០ បានផងដែរ។ អ្នកស្រីសុភាត់ ទំពុក, អ្នកស្រីចាត់ផា ចាំនៃ, លោកកលន បុលយ៉ឹក, លោកថារាំងសុម ច័ត់សាំង, លោកមួន ទូលីយ, លោកក៏ធីយ បុនិក, និងលោកផ្កាវ៉ាត់ មះល្បះឿង ជួយទំនាក់ទំនង។
- អ្នកស្រីសេះសើចន ខត្តសាប់ ស្ថាប័ណ្ណជំនាញការបាព្យព្យូធំ (ចាំងកក) អ្នកផាទំនាក់ទំនងក្នុងការបោះពុម្ពគ្រប់ផ្នែក។
- បុគ្គលិក មជ្ឈមណ្ឌលស្រាវជ្រាវរោគរបេង ស្ថាប័ណ្ណស្រាវជ្រាវនៃប្រទេសជប៉ុន ជួយទំនាក់ទំនងអ្នកជំងឺ អ្នកស្រីនុជុមធុន ផាន់ចិមផាយ អ្នកស្រីផាត់ចះវិន ផុងនៃ អ្នកស្រីមាលីរ៉ាត់ សាំមផាន់ផាត់ស៊ីទ្ធិ លោកនៃជ្រី ខ្វូនិន អ្នកស្រីសាយយុត មូលះផង អ្នកស្រីវិភក់ធុក ព្រាក់មូលការ។
- សម្ព័ន្ធមិត្រភាពពិស្ថាប័ណ្ណការមូលនិធិសុខាភិបាលប្រទេសស្វីដែន បរិចាគជាបន្ទុំយចំនួន ៩,២៥៧.៤០ បាត។
- អ្នកស្រី Lisa Imadzu ជាអ្នកសំរួលផ្នែក អក្ខរះភាសា សំនួន (ត័ងទួល)។

អត្ថបទនេះមានសារៈប្រយោជន៍សូមជូនដល់សហគម សិស្ស និស្សិត និងអ្នកសិក្សា បើមានការខុសខ្វះអត្ថន័យ អក្ខរះ សូមមេត្តាអត់ទោសក៏យោគសដល់សំណាក់យើងខ្ញុំផង។

ជិន្ទតា ឆាំងវិទ្យាផល្យ-យ៉ាំងណៃ

បណ្ណាគារខាងក្បាង

មិថុនា ២៥៥៣។



## ប្រវត្តិរបស់មូលនិធិ

ជំងឺរបេងនិងជំងឺអេដស៍ជាបញ្ហាគួរបលត្ថ ក្រសួងសុខាភិបាលត្រូវតែប្រញាប់ប្រញាល់រៀបចំដោះស្រាយ ដែលទាំងជាបញ្ហាធំសន្ធាបស់ប្រទេសថៃ ក្នុងអំឡុងឆ្នាំ គ.ស.២៥៣៥។ ក្រុមអ្នកសិក្សាពិជ្ជាបព្រជ្ញាក់ពីក្រុមជនជាតិថៃនិងជនជាតិជប៉ុន បានរួមគ្នាជួយស្រាវជ្រាវនិងគំរះគិតដើម្បីរកវិធីទប់ស្កាត់និងទប់ទល់ជំងឺរបេង, ជំងឺអេដស៍។ កន្លែងសំរាប់សិក្សាស្រាវជ្រាវនៅខេត្តលាងពាយ។ សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមអ្នកសិក្សាបានតិចតួចបរិបូណ៌ដើម្បីសម្រេចគំរះគិតក្នុងការស្រាវជ្រាវនិងទប់ស្កាតជាមួយនិងជំងឺរបេង, ជំងឺអេដស៍។ មានថ្លៃនិងមានតំលៃក្នុងការស្រាវជ្រាវជាងមួយទស្សវត្សិមកហើយ បានលទ្ធផលក្នុងការសំរួលបញ្ហាដែលមានភ្លឺថិតាក ដូចជា ជំងឺរបេង, ជំងឺអេដស៍ត្រូវតែសហការរួមគ្នានិងជួយត្រួតត្រាក្នុងការស្រាវជ្រាវប័ង្កើតអប់រំអោយបានគ្រប់ថ្នាក់ទាំងថ្នាក់ក្រុមអ្នកស្រាវជ្រាវទាំងនិប្រជុំជន ក្នុងប្រទេសនិងក្រៅប្រទេស។

ដូច្នេះហើយបានមានមូលនិធិសំរាប់ស្រាវជ្រាវជំងឺរបេង, ជំងឺអេដស៍ ជាគោលបានមួយសំរាប់បើកស្ទួយអោយមានការស្រាវជ្រាវអោយសម្ពុចបានតឹកតល់ ដើម្បីកសាងនិងកំនត់តាំងឧបវិបាករបស់ជំងឺរបេង, ជំងឺអេដស៍។ មូលនិធិបានចុះសំរុំគ្នាធ្វើសំបុត្រស្នាមតាមច្បាប់ដោយត្រឹមត្រូវ ក្នុងខែមិថុនា ២៥៤៥ ជាអង្គការមិនស្វែងរកប្រាក់ចំណេញ មានគោលការដើម្បីធ្វើការសិក្សាស្រាវជ្រាវផ្នែកខាងវិទ្យាសាស្ត្រ, សង្គមសាស្ត្រ, និងស្ថាប័ណ្ណទប់ស្កាត់ការរាលដាលជំងឺរបេង, ជំងឺអេដស៍និងជាបញ្ហារបស់ក្រសួងសុខាភិបាលដែលត្រូវបញ្ឈប់ ហើយជួយត្រួតត្រាក្នុងការឧបត្ថម្ភដល់ការអប់រំនិងអភិវឌ្ឍន៍បុគ្គលិកផ្នែកខាងពេទ្យនិងក្រសួងសុខាភិបាលបញ្ចូលដល់ជួយផ្នែកការណែនាំប្រឹក្សាផ្លូវវិជ្ជាការទាក់ទងនិងជំងឺរបេង, ជំងឺអេដស៍។

ប្រធាននិងគណៈកម្មការមូលនិធិ

ប្រធានវេជ្ជ: បណ្ឌិត ជិន្ទតា ឆាយវិទ្យាផល្យ-យ៉ាំងៃណ พ.บ. (เกียรตินิยม), ศศ.ม, PhD.

អនុប្រធាន វេជ្ជៈបណ្ឌិត ពាក់ធុម សះវណ្ណបញ្ញាលើត พ.บ. (เกียรตินิยม) Dr. P.H.

គណៈកម្មការ ផាវេត ញ្ញូស៊ី พ.บ, M.P.H.

គណៈកម្មការនិងហេរញ្ញិក ប៊ុំយះនុត ផាត់វរ៉ាត់ ศ.บ

គណៈកម្មការនិងលេខាធុការ សាយយុត មូលះផង พ.บ, M.P.H.

# ការផ្តល់ចំណេះដឹងជាបុណ្យកុសលដ៏ប្រសើរ

អត្ថបទដ៏មានខ្លឹមសារនេះ កើតឡើងដោយពីការព្យាយាមរបស់ក្រុមអ្នកស្រាវជ្រាវ ដែលជួបប្រទះឃើញបញ្ហាខ្វះខាតការយល់ដឹងទាក់ទងនិងជំងឺរបេង, ជំងឺអេដស៍ ម្យ៉ាងទៀតបញ្ហារបស់សង្គមមានការស្អប់ខ្ពើមអ្នកជំងឺ និងបញ្ហាអ្នកជំងឺមានការរុញរាដកថយចិត្តនិងអស់ក្តីសង្ឃឹម បញ្ហាចុងក្រោយគឺជួបប្រទះឃើញបុគ្គលិកសុខាភិបាលមានការរុញរាចិត្តក្នុងការថែរក្សាអ្នកជំងឺ តែក្រុមអ្នកស្រាវជ្រាវក៏បានតំរះគិតថា ការផ្តលចំណេះដឹងនិងការជឿជាក់ដែលត្រឹមត្រូវជាមួយនិងជំងឺ អាចដោះស្រាយនិងបញ្ហាផ្សេងៗបាន ដូច្នេះហើយក្រុមអ្នកស្រាវជ្រាវទើបនាំយកចំណេះវិជ្ជានិងការប៉ិនប្រសប់ដែលជាទេពកុសលពីក្រុមអ្នកស្រាវជ្រាវអោយមកបានកើតជាអត្ថបទនេះ។

បើសិនលោកអ្នកយល់ថារូបមន្តនេះមានផលប្រយោជន៍សំខាន សូមមេត្តាជួយផ្សព្វផ្សាយអោយចំណេះដឹងដល់អ្នកដ៏ទៃផង។សម្រាប់មជ្ឈមណ្ឌលសហគម អង្គការ ដែលត្រូវការនាំយកអត្ថបទនេះទៅផ្តល់ចំណេះយល់ដឹង ឫផ្តល់ក្នុងការអប់រំដល់អ្នកជំងឺ សិស្ស និសិត និងអ្នកសិក្សាព្រមទាំងប្រជាជនទូទៅ លោកអ្នកអាចទំនាក់ទំនងទទូលសៀវភៅនេះ បាននៅមូលនិធិស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍ ។

## បើសិនអស់លោក,លោកអ្នកមានសទ្ធាជ្រះថ្លាចង់ចូលបុណ្យ

- សូមទំនាក់ទំនងការិយាល័យមូលនិធិស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍
  លេខទី: 1050/2 វិថីស្ថានផ្សាបាន ស្រុកមឿង ខេត្តឈាងរាយ 57000
  ទូរស័ព្ទលេខ: 085-3752-162, 081-764-2400
  លេខហ្វាក់: 085-3752-448 email: thrf@tbhiv.org ។
- បរិចាគបច្ច័យបញ្ចូលបញ្ជីមូលនិធិស្រាវជ្រាវជំងឺរបេងនិងជំងឺអេដស៍ ធនាគារកសិករថៃ សាខាឈាងរាយលេខបញ្ជី 154-2-76033-4 ។